

# តំបន់ព្រៃឡង់

ការសិក្សាវាយតម្លៃជីវៈចម្រុះសម្រាប់
រដ្ឋបាលព្រៃឈើ
រៀបចំដោយអង្គការអភិរក្សអន្តរជាតិ
និងអង្គការវីនរ៉ក់អន្តរជាតិ

# តំបន់ព្រៃឡង់

## ការសិក្សាវាយតម្លៃជីវៈចម្រុះសម្រាប់ រដ្ឋបាលព្រៃឈើ

រៀបចំដោយអង្គការអភិរក្សអន្តរជាតិ
និងអង្គការវីនរ៉ក់អន្តរជាតិ

USAID FROM THE AMERICAN PEOPLE
WINROCK INTERNATIONAL
CONSERVATION INTERNATIONAL Cambodia

រូបភាពទាំងអស់ថតដោយ © Jeremy Holden នៃអង្គការអភិរក្សអន្តរជាតិ លើកលែង
តែមានការកំណត់ផ្សេងពីនេះ។
រចនាដោយ © Jeremy Holden។



# មាតិកា


សេចក្តីថ្លែងអំណរគុណ ..... 5
ការសិក្សាស្រាវជ្រាវ ..... 6
ការណែនាំអំពីព្រៃឡង់ ..... 8
ព្រៃល្បោះ ..... 9
ព្រៃស្រោង ..... 12
ព្រៃជាំទឹក ..... 14
ការកកើតឡើងនៃស្រទាប់ថ្ម Karst ..... 16
ដំរី ខ្ទីង និងទន្សោង ..... 18
ម៉ាស៊ីនថតរូបស្វ័យប្រវត្តិ ..... 20
សត្វស្លាប ..... 22
ឧរង្គសត្វ និងថលជលិក ..... 24
សត្វឥតឆ្អឹងកង ..... 26
រុក្ខជាតិ ..... 28
ធារាសាស្ត្រ ..... 30
ការប្រមូលផលទឹក ..... 32
ការកាប់បំផ្លាញព្រៃឈើ ..... 33
ការជួញដូរសត្វព្រៃ ..... 36
សារៈសំខាន់នៃការការពារព្រៃឡង់ ..... 38
អាស័យដ្ឋាន ..... 41

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះ **ឯកឧត្តម បណ្ឌិត ឆេង គឹមស៊ុន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ បណ្ឌិត កែវ អូម៉ាលីស ប្រធាននាយកដ្ឋានសត្វព្រៃ និងជីវៈចម្រុះ និង លោក សៅវណ្ណនី ប្រធានផ្នែករដ្ឋបាលព្រៃឈើសណ្ដាន់ ខេត្តកំពង់ធំ។

ក្រុមការងារស្រាវជ្រាវសូមអរគុណចំពោះ ការជួយជ្រោមជ្រែងរបស់អាជ្ញាធរមូលដ្ឋាន និងប្រជាជននៅក្នុងភូមិក្រែន ឃុំទំរីង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ភូមិសៀមបូក ខេត្តស្ទឹងត្រែង ភូមិស្មៀង ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង លោក ឡុង សំផាត ជាមេឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ ភូមិភ្វាក់រលឹក ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ ភូមិស្ដង់ ឃុំអន្លង់ភេ ស្រុងថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង និងលោកស្រី ភោគ ហុង គណៈកម្មការសម្របសម្រួលព្រៃឡង់ ភូមិភ្វាក់រលឹក ឃុំផ្ទា ស្រុកជ័យសែន ខេត្តព្រះវិហារ។

សូមអរគុណជាពិសេសចំពោះក្រុមការងារដូចជា លោក ឡា ប៉េងលី និងបុគ្គលិកបច្ចេកទេសអង្គការអភិរក្សអន្តរជាតិ លោក ឃូ អៀងហួត លោក ឈិន សុភា លោក នាង ធី លោក Ben Hayes លោក Jeremy Holden និងលោក Neil Furey។ សម្រាប់ការជួយកែសម្រួល សូមអរគុណចំពោះ Ida Theilade, Marcus Hardtke, David Ashewell, Joe Walston, Alex Diment, Fredric Goes, Howie Nielson, David Ware និង បុគ្គលិកអង្គការវីនរ៉ក់ អន្តរជាតិ។

សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (**USAID**) ដែលជាម្ចាស់ជំនួយរបស់គម្រោងគាំទ្រព្រៃឈើ និងជីវចម្រុះដែលបានផ្ដល់ថវិកាគាំទ្រចំពោះការសិក្សាស្រាវជ្រាវនេះ។



# ការសិក្សាស្រាវជ្រាវ

ព្រៃឡង់ គឺជាព្រៃដ៏សំខាន់បំផុតមួយនៅក្នុងប្រទេសកម្ពុជាដែលមិនមែនជាព្រៃការពារ ហើយនៅក្នុងឆ្នាំ២០១៤ រដ្ឋបាលព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា បានស្នើសុំឲ្យមានការសិក្សាស្រាវជ្រាវមួយដើម្បីវាយតម្លៃជីវៈចម្រុះដែលមាននៅក្នុងតំបន់ព្រៃឡង់នេះ។

ក្រោមជំនួយមូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) និងក្នុងភាពជាដៃគូជាមួយអង្គការវីនរ៉ក់អន្តរជាតិ អង្គការអភិរក្សអន្តរជាតិ បានរៀបចំអ្នកជំនាញជាតិ និងអន្តរជាតិមួយក្រុមឲ្យធ្វើការសិក្សាស្រាវជ្រាវអំពីភាពសម្បូរបែប និងភាពចម្រុះគ្នានៃប្រភេទសត្វ និងរុក្ខជាតិនៅក្នុងតំបន់ព្រៃឡង់។ ដោយបញ្ចប់នៅដើមឆ្នាំ២០១៥ ការសិក្សាស្រាវជ្រាវអំពីជីវៈចម្រុះនេះ បានរកឃើញថាតំបន់ព្រៃឡង់ផ្ដល់ជាជម្រកដល់ការរស់នៅរបស់ប្រភេទសត្វ និងរុក្ខជាតិជាច្រើនប្រភេទ រួមបញ្ចូលទាំងសត្វ និងរុក្ខជាតិចំនួន៥៥ប្រភេទដែលស្ថិតនៅក្នុងបញ្ជីរបស់អង្គការ IUCN និងជាប្រភេទទទួលរងនូវការគំរាមកំហែង។

របាយការណ៍បច្ចេកទេសលម្អិតទាំងស្រុងនៃការសិក្សាស្រាវជ្រាវនេះ អាចរកបាននៅការិយាល័យអង្គការអភិរក្សអន្តរជាតិ ដែលមានទីតាំងស្ថិតនៅទីក្រុងភ្នំពេញ។ (សូមមើលអាស័យដ្ឋានទំព័រចុងក្រោយ)



# ការណែនាំអំពីព្រៃឡង់

តំបន់ព្រៃឡង់ មានទីតាំងស្ថិតនៅភាគខាងលិចទន្លេមេគង្គក្នុងផ្នែកកណ្តាល ប៉ែកខាងជើងនៃប្រទេសកម្ពុជា និងលាតសន្ធឹងក្នុងខេត្តចំនួន៤ គឺ ក្រចេះ កំពង់ធំ ស្ទឹងត្រែង និងព្រះវិហារ។ ព្រៃនេះក៏មានប្រភពទឹកចំនួន៣ ដូចជា ស្ទឹងសែន ស្ទឹងជីនិត និងសៀមបូក ព្រមទាំងជាកន្លែងធារាសាស្រ្តឆ្លងកាត់ រវាងទន្លេសាប និងអាងទឹកទន្លេមេគង្គ។

ព្រៃឡង់ គឺជាព្រៃស្រោងតំបន់ទំនាបធំជាងគេបង្អស់នៅកម្ពុជា និងប្រហែល ជាមានតម្លៃបំផុតនៅក្នុងតំបន់ឥណ្ឌូភូមា។

តំបន់ព្រៃឡង់នេះ ផ្តល់នូវសេវាកម្មបរិស្ថានសំខាន់ៗជាច្រើន រួមបញ្ចូល ទាំងជីវភាពរស់នៅរបស់ប្រជាសហគមន៍ និងការការពារទីជម្រាល។ តំបន់ ព្រៃឡង់នេះ ក៏ផ្តល់ជាទីជម្រកដ៏សំខាន់បំផុតមួយសម្រាប់សត្វព្រៃជាច្រើន ប្រភេទដែលកំពុងទទួលរងការគំរាមកំហែងនៅទូទាំងប្រទេស។



# ព្រៃល្បោះ

ដោយភាគច្រើនជាដីទំនាបស្មើ ព្រៃឡង់សំបូរទៅដោយទីជម្រកដ៏សម្បូរបែបដូចជាព្រៃល្បោះ និងព្រៃពាក់កណ្តាលស្រោង ព្រៃស្រល់ និងវាលស្មៅ បើទោះបីជាភាគច្រើននៃគម្របព្រៃនៅតំបន់ព្រៃឡង់នេះជាប្រភេទព្រៃស្រោងក្តី។ ព្រៃស្រោងជាំទឹកមានប្រភពទឹកជាប្រចាំដែលអាចធានាដល់ការប្រើប្រាស់របស់ប្រជាមូលដ្ឋាន និងសត្វព្រៃបានពេញរដូវប្រាំង។ ការកកើតឡើងនៃស្រទាប់ថ្ម Karst ដ៏អស្ចារ្យ និងតាមបែបជីវសាស្ត្រក៏មាននៅភាគខាងជើងក្នុងតំបន់ព្រៃឡង់នេះដែរ។



# ព្រៃស្រោង

ព្រៃស្រោង សំបូរទៅដោយសត្វ និងរុក្ខជាតិជាច្រើនប្រភេទ រាប់ចាប់ពីប្រភេទសត្វរស់នៅលើដី រហូតដល់ស្រទាប់ក្រោមដី។ ទីជម្រកដ៏ពិសេសនេះ ដែលជារឿយៗត្រូវបានគេស្គាល់ថាជាព្រៃសំបូរភ្លៀង មានផ្កាថ្មតំបន់ត្រូពិច និងទ្រទ្រង់ការរស់នៅរបស់សត្វជាច្រើនប្រភេទនៅលើភពផែនដី។










# ព្រៃជាំទឹក

នៅផ្នែកកណ្តាលព្រៃឡង់ គ្របដណ្តប់ទៅដោយផ្ទៃទឹកដ៏ធំទូលាយនារដូវវស្សា និងក្លាយទៅជាថ្លុកទឹកតូចៗនៅរដូវប្រាំង។ តំបន់ដក់ទឹកជាច្រើនកន្លែងដូចជា ត្រពាំង និងបឹង ផ្តល់ជាទីជម្រកដ៏សំខាន់សម្រាប់សត្វព្រៃច្រើនប្រភេទជាពិសេស ប្រភេទសត្វស្លាបដូចជា សត្វនាលពណ៌ (*Mycteria leucocephala*) និងសត្វស្មោញ (*Anhinga*) ជាដើម។ ប្រជាជនក៏ពឹងអាស្រ័យទៅលើប្រភពទឹកទាំងអស់នេះ សម្រាប់ស្រោចដំណាំផងដែរ។

ព្រៃស្រោងជាំទឹកនៅក្នុងតំបន់ព្រៃឡង់ដែលមានភាពត្រជាក់ និងស្ងប់ស្ងាត់ ពិតជាមានតែមួយគត់នៅក្នុងប្រទេសកម្ពុជា។ ដោយមានភាពខុសប្លែកពីគ្នា នៃអេកូឡូស៊ីពីព្រៃជាំទឹកនៅបឹងទន្លេសាប និងស្ទឹងសែន ទីជម្រកធម្មជាតិដ៏ពិសេសមួយនេះ គាំទ្រដល់ការរស់នៅរបស់សត្វរស់នៅក្នុងទឹក និងលើគោក ជាច្រើនប្រភេទ ហើយដើរតួនាទីជាអេកូឡូស៊ីដ៏មានតម្លៃក្នុងការជួយរក្សាប្រភពទឹកក្រោមដីនៅរដូវប្រាំងទៀតផង។








# ការកកើតឡើងនៃ ប្រភេទថ្ម Karst

ការកកើតឡើងនៃស្រទាប់ថ្ម Karst ដ៏ធំមួយ មានកើតឡើងនៅភាគខាងជើងនៃតំបន់ព្រៃឡង់។ តំបន់ថ្ម Karst ប្រភេទនេះជាតំបន់ដ៏កម្រនៅកម្ពុជា និងមានការយកចិត្តទុកដាក់តិចតួចបំផុតនៅក្នុងបណ្ដាញតំបន់ការពាររបស់កម្ពុជា។

ការកកើតឡើងនៃប្រភេទថ្ម Karst ត្រូវបានគេស្គាល់តាមរយៈរូងភ្នំ ដែលជាកន្លែងមានជីវៈចម្រុះរស់នៅគ្រប់ប្រភេទសត្វដែលមានតាមតំបន់និងរងការគំរាមកំហែង។អំឡុងពេលស្រាវជ្រាវ ក៏មានការសិក្សាមួយផងដែរអំពីក្រុមសត្វប្រជៀវ។ សត្វប្រជៀវចំនួន២៤ប្រភេទត្រូវបានគេរកឃើញដូចជា សត្វប្រចៀវ Marshall’s horseshoe ( *Rhinolophus marshalli)* ដែលជាប្រភេទសត្វប្រចៀវទើបរកឃើញថ្មីនៅក្នុងប្រទេសកម្ពុជា។ ៧៩ ភាគរយនៃប្រភេទសត្វប្រចៀវទាំងនេះ ត្រូវបានគេរកឃើញនៅក្នុងតំបន់ថ្ម Karst ភាគខាងជើង។

ព្រៃឡង់ទ្រទ្រង់ការរស់នៅរបស់សត្វប្រចៀវយ៉ាងហោចណាស់១ភាគ៣នៃប្រភេទសត្វប្រចៀវទាំងអស់ ដែលរស់នៅក្នុងប្រទេសកម្ពុជា។ ព្រៃឡង់ និងការកកើតឡើងនៃថ្ម Karst ភាគខាងជើង គឺពិតជាមានសារៈសំខាន់បំផុតសម្រាប់ការអភិរក្សសត្វប្រចៀវនៅកម្ពុជា។



© Neil Furey x 4



# ដំរី ខ្ទីង និងទន្សោង

បណ្តុំព្រៃនៅក្នុងតំបន់ព្រៃឡង់ គឺជាទីជម្រកដ៏សំខាន់សម្រាប់ថនិកសត្វមានមាឌធំបំផុតចំនួនបីប្រភេទនៅក្នុងប្រទេសកម្ពុជា គឺដំរីអាស៊ី ខ្ទីង និងទន្សោង។

ថនិកសត្វធំៗទាំងបីប្រភេទនេះ កំពុងទទួលរងការគំរាមកំហែងនៅទូទាំងផ្ទៃប្រទេសដោយសារការបាត់បង់ទីជម្រក។ ទីជម្រកដ៏សំបូរបែបនៅក្នុងតំបន់ព្រៃឡង់មិនត្រឹមតែជាធនធានដ៏សំខាន់សម្រាប់ចំនួនថនិកសត្វមានមាឌធំបំផុត ដែលនៅសេសសល់ប៉ុណ្ណោះទេ វាថែមទាំងផ្តល់នូវទីជម្រកដ៏ប្រពៃ សម្រាប់ការស្តារឡើងវិញនូវប្រភេទសត្វដែលកំពុងបាត់បង់ និងរងការគំរាមកំហែងផងដែរ។

ការសិក្សាស្រាវជ្រាវ បានរកឃើញចំនួនសត្វដំរីយ៉ាងហោចណាស់ចំនួន១៣ក្បាល ហើយបានប៉ាន់ប្រមាណថាមានចំនួនសត្វដំរីប្រហែលជាង២០ក្បាលកំពុងរស់នៅតំបន់ព្រៃឡង់។ ចំនួនសត្វដំរីដែលរកឃើញនេះដែរ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ចំនួនសត្វដំរីដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា។









# ម៉ាស៊ីនថតរូបស្វ័យប្រវត្តិ

ជារួម ថនិកសត្វចំនួន៣៦ប្រភេទត្រូវបានរកឃើញនៅក្នុងតំបន់ព្រៃឡង់ទាំងមូល ក្នុងកំឡុងពេលធ្វើការសិក្សាស្រាវជ្រាវនេះ។ ការរកឃើញប្រភេទសត្វជាច្រើននេះ គឺតាមរយៈការប្រើប្រាស់ម៉ាស៊ីនថតរូបស្វ័យប្រវត្តិដើម្បីថតរូបសត្វដែលរស់នៅតំបន់ដាច់ស្រយាល។

ប្រភេទសត្វភាគច្រើន គឺលំបាកនឹងរកឃើញណាស់ ពីព្រោះពួកវាជាសត្វងាយផ្អើល និងជាប្រភេទសត្វកម្រ ឬក៏ចូលចិត្តចល័តតែពេលយប់។ ម៉ាស៊ីនថតរូបស្វ័យប្រវត្តិទាំងនេះ ដែលគេដាក់ទុកចោលអស់រយៈពេលជាច្រើនខែនៅក្នុងព្រៃ គឺជាមធ្យោបាយដ៏ល្អបំផុតមួយដើម្បីកត់ត្រាពីប្រភេទសត្វដែលកម្រឃើញទាំងអស់នោះ

ជាឧទាហរណ៍ សត្វស្វាព្រាម (*Trachypithecus germaini*) ដែលជាប្រភេទសត្វរស់នៅលើដើមឈើ និងងាយស្រួលឃើញ ក៏ពុំត្រូវបានគេប្រទះឃើញអំឡុងពេលធ្វើការស្រាវជ្រាវថនិកសត្វនេះដែរ ប៉ុន្តែពួកវា ត្រូវថតជាប់ជាញឹកញាប់ដោយម៉ាស៊ីនថតរូបស្វ័យប្រវត្តិនៅតាមថ្លុកទឹកនានា។

ម៉ាស៊ីនថតរូបស្វ័យប្រវត្តិ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ថតប្រភេទសត្វ ដែលមានភាពអៀនខ្មាស់ ស្ងប់ស្ងាត់ ឬក៏ប្រភេទសត្វស្លាបរស់នៅលើដីដូចជាមាន់ទោរពណ៌ប្រាក់ជាដើម។









# សត្វស្លាប

តំបន់ព្រៃឡង់ គឺជាទីជម្រកសត្វស្លាបជាតិដ៏សំខាន់មួយ ដែលក្នុងនោះក្រុមអ្នកស្រាវជ្រាវបានរកឃើញសត្វស្លាបចំនួន ២៦៦ ប្រភេទកំពុងរស់នៅក្នុងតំបន់ព្រៃឡង់។ ចំនួននេះស្មើនឹង៤៤% នៃប្រភេទសត្វស្លាបទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជា។

សត្វស្លាបចំនួន១៥ប្រភេទដែលមានកត់ត្រាក្នុងបញ្ជីក្រហមរបស់អង្គការ IUCN រួមបញ្ចូលទាំងសត្វដែលមានតាមតំបន់ និងជាសកល ដូចជាសត្វកេងកងធំ (*Buceros bicornis*) ក៏ត្រូវបានក្រុមអ្នកស្រាវជ្រាវរកឃើញនៅទីនោះផងដែរ។ ប្រភេទសត្វស្លាបសំខាន់ៗផ្សេងទៀតក្នុងចំណោមនោះ មានដូចជា ទទាទ្រូងលឿង (*Arborophila davidi*) ក្ងោក (*Pavo muticus*) ត្រសេះដំរី (*Mulleripicus pulverulentus*) និងត្រដក់ធំ (Leptoptilos dubius)។

ត្រដក់តូច (*Leptoptilos javanicus*) និង សត្វកស ឬត្រុំ (*Ciconia episcopus*) រស់នៅតាមត្រពាំង និងវាលស្មៅទៅតាមរដូវកាល។ ប្រភេទសត្វស្លាបទឹកមានមាឌធំដែលទទួលរងការគំរាមកំហែងជាសកលផ្សេងទៀតដូចជា សត្វត្រយងយក្ស (*Thaumatibis gigantea*) ត្រយងចង្កំកស (*Pseudibis davisoni*) និងសត្វក្រៀល (*Grus Antigone*) ត្រូវបានប្រជាជនមូលដ្ឋានផ្តល់ដំណឹងឲ្យយ៉ាងច្បាស់អំពីវត្តមានរបស់ពួកវា ហើយពួកវាក៏ទំនងជាប្រើប្រាស់ត្រពាំងទាំងនោះជាញឹកញាប់ផងដែរ។









# ឧរង្គសត្វ និងថលជលិក

ថលជលិកសរុបចំនួន ២២ប្រភេទ និងឧរង្គសត្វចំនួន ៤៥ប្រភេទ ត្រូវបានក្រុមអ្នកស្រាវជ្រាវរកឃើញនៅក្នុងតំបន់ព្រៃឡង់ រួមទាំងប្រភេទសត្វជាច្រើនដែលមាននៅក្នុងបញ្ជីក្រហមរបស់អង្គការ IUCN។ ឧរង្គសត្វថ្មីមួយប្រភេទ *Gekko petricolus* ត្រូវបានក្រុមអ្នកស្រាវជ្រាវប្រទះឃើញនៅក្នុងតំបន់ព្រៃឡង់ ក្នុងអំឡុងពេលសិក្សាស្រាវជ្រាវ ហើយក៏ជាលើកដំបូងបង្អស់ផងដែរសម្រាប់ប្រទេសកម្ពុជា។

របាយ និងវត្តមានដ៏ច្រើនបំផុតរបស់ប្រភេទឧរង្គសត្វ និងថលជិកដែលជាប្រភេទសត្វទទួលរងការគំរាមកំហែងជាសកលដែលមានវត្តមានរស់នៅក្នុងតំបន់ព្រៃឡង់គឺជាចំនុចវិជ្ជមានមួយ ដោយសារប្រភេទសត្វទាំងអស់នេះគឺជាសូចនាករនៃបរិស្ថានដ៏ល្អមួយ។

ជារួម វាមិនទាន់ហួសពេលនៅឡើយទេដើម្បីការពារតំបន់ព្រៃឡង់ ប៉ុន្តែប្រភេទឧរង្គសត្វ និងថលជលិកជាច្រើនផ្សេងទៀតនៅក្នុងតំបន់នេះ កំពុងរងគ្រោះថ្នាក់ពីការបរបាញ់សម្រាប់ធ្វើជាអាហារ និងអាជីវកម្ម។








# សត្វឥតឆ្អឹងកង

មិនមែនជាការភ្ញាក់ផ្អើលទេ ខណៈតំបន់ព្រៃឡង់ដែលគ្របដណ្តប់ទៅដោយព្រៃតំបន់ត្រូពិចដ៏ធំមួយ គឺជាទីជម្រកសម្រាប់សត្វឥតឆ្អឹងកងជាច្រើនប្រភេទ និងសម្រាប់សត្វជាច្រើនប្រភេទផ្សេងទៀតដែលក្រុមអ្នកវិទ្យាសាស្ត្រមិនទាន់បានរកឃើញ។ ក្នុងអំឡុងពេលស្រាវជ្រាវនេះមានសត្វជាច្រើនប្រភេទត្រូវបានក្រុមអ្នកស្រាវជ្រាវរកឃើញនៅតាមកន្លែងជាច្រើនក្នុងតំបន់ព្រៃឡង់ ដូចជាសត្វកន្ទុំរុយ ដែលមានមាឌតូចបំផុត (*Nannophya pygmaea*) នៅលើពិភពលោក (រូបខាងឆ្វេង) សត្វពីងពាងរូបរាងចម្លែក (*fearsome-looking whip spiders*) និងសត្វក្អែប (*scutigerid centipedes*) ដែលរស់នៅតំបន់រូងភ្នំថ្មកំបោរ។










# រុក្ខជាតិ

ក្នុងចំណោមរុក្ខជាតិជាច្រើនប្រភេទនៅក្នុងតំបន់ព្រៃឡង់ មានរុក្ខជាតិ និងដើមឈើចំនួន ១១ប្រភេទ ស្ថិតនៅក្នុងបញ្ជីក្រហមរបស់អង្គការIUCN។ រុក្ខជាតិសំខាន់ចំនួន ១៥ប្រភេទ ក្នុងចំណោម ២០ប្រភេទ ដែលកំណត់ដោយគម្រោងគ្រាប់ពូជឈើកម្ពុជារបស់រដ្ឋបាលព្រៃឈើឆ្នាំ២០០៣ ក៏ត្រូវបានរកឃើញនៅក្នុងតំបន់ព្រៃឡង់ដែរ។

នៅក្នុងចំណោមរុក្ខជាតិ និងដើមឈើដែលរកឃើញទាំងអស់នោះមានប្រភេទដើម រុក្ខជាតិមំសាសី *(carnivorous pitcher plant)* (រូបភាពខាងក្រោម) និងដើមអរគីដេពណ៌សដ៏កម្រ *(white orchid)* ដែលនេះជាលើកដំបូងដែលក្រុមអ្នកស្រាវជ្រាវប្រទះឃើញនៅប្រទេសកម្ពុជា។









# ធារាសាស្ត្រ

តំបន់ព្រៃឡង់ គឺជាអាងស្តុកទឹកដ៏សំខាន់មួយសម្រាប់បឹងទន្លេសាប ហើយព្រៃឈើតំបន់នេះជួយកាត់បន្ថយការហូរកាកសំណល់ទៅក្នុងទីជម្រកសម្រាប់ជលផលដ៏សំខាន់នេះ។ ការកាប់ឈើខុសច្បាប់ កំពុងផ្លាស់ប្តូរសមាសភាព និងរចនាសម្ព័ន្ធព្រៃឈើ ព្រមទាំងផ្លាស់ប្តូរអាកាសធាតុទីនោះ និងបង្កើនដីល្បាប់នៅតាមផ្លូវទឹក។ បញ្ហាទាំងអស់នេះមិនត្រឹមតែមានផលប៉ះពាល់ដល់ការបាត់បង់ទីជម្រក និងកន្លែងបន្តពូជសម្រាប់វារីជាតិប៉ុណ្ណោះទេ ប្រសិនបើមិនមានការត្រួតពិនិត្យទេនោះ វានឹងអាចមានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរនៅប៉ែកខាងក្រោមទន្លេ។

ព្រៃក្នុងតំបន់ព្រៃឡង់ ក៏រួមចំណែកទប់ស្កាត់ទឹកជំនន់នៅរដូវវស្សាចន្លោះពីខែសីហា ដល់ខែកញ្ញាផងដែរ ហើយត្រូវបានគេជឿជាក់ថា រួមចំណែកយ៉ាងចំបងដល់ការរក្សាទឹកក្រោមដីនារដូវប្រាំង។

សេវាកម្មបរិស្ថានដ៏ចាំបាច់ទាំងអស់នេះគួរតែត្រូវបានគិតគូរយ៉ាងយកចិត្តទុកដាក់នៅក្នុងកិច្ចពិភាក្សានានាស្តីអំពីការអភិវឌ្ឍនាពេលអនាគត ឫក៏ការការពារតំបន់ព្រៃឡង់។





# ការប្រមូលជ័រទឹក



ប្រជាសហគមន៍ជាង ២៥០,០០០នាក់រស់នៅក្នុងភូមិចំនួន៣៤០ ដែលស្ថិតនៅក្នុង និងជុំវិញតំបន់ព្រៃឡង់ពឹងអាស្រ័យស្ទើរតែទាំងស្រុងទៅលើតំបន់ព្រៃឡង់សម្រាប់ជីវភាពរស់នៅ។ ប្រជាជនភាគច្រើន គឺជាជនជាតិដើមភាគតិចគួយ ហើយព្រៃឈើគឺជាផ្នែកមួយនៃវប្បធម៌ និងជំនឿសាសនារបស់ពួកគេ។

ការប្រមូលក្រវាញ ទឹកឃ្មុំព្រៃ ផ្តៅ ឫស្សី និងផ្លែឈើព្រៃ គឺជាសកម្មភាពដែលអាចរកប្រាក់ចំណូលរបស់ពួកគាត់នៅក្នុងតំបន់ព្រៃឡង់នេះ។



ការចោះយកជ័រទឹក គឺជាមុខរបរចិញ្ចឹមជីវិតសំខាន់មួយសម្រាប់ប្រជាជនរស់នៅក្នុងព្រៃ ហើយជ័រទឹកជារបស់ដ៏មានតម្លៃ។ នៅតំបន់ព្រៃឡង់នេះ មានប្រភេទដើមច្បោះជ័រ *Dipterocarp* ចំនួនប្រាំប្រភេទដែលអាចផ្តល់ជាជ័រទឹកបាន។ ប្រភេទដើមច្បោះទាំងនេះរួមមានប្រភេទដើមដែលផ្តល់ជ័រទឹកចំនួនបី (០៣) ប្រភេទគឺ: *Dipterocarpus costatus, D. alatus* និង *D. intricatus* ព្រមទាំងប្រភេទដើមដែលផ្តល់ជ័រចុងចំនួន ២ ប្រភេទគឺ *Shorea obtusa* និង *S. siamensis*។ អ្នកដងជ័រទឹកមានភាពសកម្មក្នុងការការពារដើមជ័ររបស់ពួកគាត់។ កត្តានេះ នាំឱ្យមានការអភិរក្សតំបន់ព្រៃឡង់ចាំផ្តើមពីប្រជាសហគមន៍ ខណៈដែលប្រជាសហគមន៍ភាគច្រើន មិនចង់ឃើញព្រៃឈើរបស់ពួកគាត់ទទួលរងការបំផ្លាញ ពីព្រោះពេលដែលព្រៃឈើបាត់បង់ដើមច្បោះជ័រក៏ត្រូវបាត់បង់ដែរ។



# ការកាប់បំផ្លាញព្រៃឈើ

ការកាប់ឈើខុសច្បាប់ កើតមានយ៉ាងប្រត្យក្សនៅទូទាំងតំបន់ព្រៃឡង់ក្នុងអត្រាមួយខ្ពស់។ ប្រភេទឈើមានតម្លៃខ្ពស់បំផុតដូចជា ឈើបេង គឺស្ទើរតែបាត់បង់គ្មានសល់នៅតំបន់នេះ ហើយអ្នកកាប់ឈើខុសច្បាប់កំពុងតែបន្តកាប់ប្រភេទឈើមានតម្លៃបំផុតបន្ទាប់។ ដីព្រៃក៏ត្រូវបានគេកាប់ឆ្ការសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ និងអាជីវកម្ម។

បុគ្គលិកសន្តិសុខ និងកម្មករដែលជួលដោយក្រុមហ៊ុនអាជីវកម្ម ក៏រួមចំណែកក្នុងការកាប់ឈើ នេសាទ និងបរបាញ់សត្វព្រៃខុសច្បាប់ផងដែរ។

© Allan Michaud









# ការជួញដូរសត្វព្រៃ

ការជួញដូរសត្វព្រៃខុសច្បាប់ កំពុងរីកខ្លាំងនៅក្នុងតំបន់ព្រៃឡង់ ហើយប្រភេទថនិកសត្វ សត្វស្លាប និងឧរង្គសត្វជាច្រើន ត្រូវបានគេប្រទះឃើញលក់នៅក្នុងផ្សារក្នុងតំបន់ ឬក៏ត្រូវបានស្តុកទុកសម្រាប់លក់ឱ្យឈ្មួញកណ្តាល ដើម្បីនាំចេញទៅកាន់ប្រទេសចិន និងវៀតណាម។ ការបរបាញ់ បង្កការគំរាមកំហែងដល់ប្រភេទសត្វសំខាន់ៗជាច្រើនដែលមានវត្តមាននៅតំបន់ព្រៃឡង់នេះ។





© Sokrith Heng (top) & Pengly La

# សារៈសំខាន់នៃការការពារព្រៃឡង់



តម្លៃផ្នែកជីវៈចម្រុះ គួរឱ្យកត់សម្គាល់របស់ព្រៃឡង់ គឺជាឃ្លាំងស្តុកទឹក និងឱកាសសេដ្ឋកិច្ចដ៏សំខាន់របស់តំបន់ព្រៃឡង់។ កត្តានេះបង្ហាញឱ្យឃើញថា ព្រៃឡង់ត្រូវការការពារក្នុងកម្រិតខ្ពស់បំផុត។ ទោះជាយ៉ាងនេះក្តី តំបន់ព្រៃឡង់នេះកំពុងមានការផ្លាស់ប្តូរជាអវិជ្ជមាន ហើយក្នុងកម្រិតកើនឡើងមួយខ្ពស់មិនធ្លាប់មាន។ នៅទូទាំងតំបន់ព្រៃឡង់ មានការបាត់បង់ទីជម្រកគួរឱ្យកត់សម្គាល់ភាគច្រើនគឺនៅប៉ែកខាងត្បូង និងខាងជើងនៃតំបន់ព្រៃស្រោងផ្នែកកណ្តាល។

ប្រសិនបើមិនមានការធ្វើសកម្មភាពជាបន្ទាន់ណាមួយដើម្បីការពារព្រៃឡង់នោះទេ តំបន់ព្រៃដែលមានជីវៈចម្រុះដ៏មានតម្លៃ និងសេវាកម្មព្រៃឈើ ដែលផ្តល់កម្រៃច្រើនមួយនេះនឹងត្រូវបាត់បង់ជារៀងរហូត។


*Man did not weave the web of life, he is merely a strand in it.*
*Whatever he does to the web, he does to himself.*

## អាសយដ្ឋាន


អង្គការអភិរក្សអន្តរជាតិ
ប្រអប់សំបុត្រលេខ៖ ១៣៥៦
ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ +855 (023) 214 627
Info-cicambodia@conservation.org
www.conservation.org

អង្គការវីនរ៉ក់អន្តរជាតិ
គម្រោងគាំទ្រព្រៃឈើ និងជីវចម្រុះរបស់ USAID
បន្ទប់លេខ ៥៨៨ អាគារ F មជ្ឈមណ្ឌលភ្នំពេញ
មហាវិថីសុធារស ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ៖ +855 (0)23 220 714
infosfb@winrock.org


USAID
FROM THE AMERICAN PEOPLE
WINROCK
INTERNATIONAL
CONSERVATION
INTERNATIONAL
Cambodia